

# ជំពូកទី១៣

# ទប់ស្កាត់ការរំលោភបំពានផ្លូវភេទកុមារ

មើលទៅវាអាចជារឿងចម្លែកបន្តិចក្នុងការរកឃើញព័តិមាន អំពីការរំលោភបំពានផ្លូវភេទកុមារនៅក្នុងសៀវភៅ "ការជួយកុមារមិនអាចស្តាប់ឮ" ។ ប៉ុន្តែរឿងគួរឱ្យសោកស្តាយបំផុតនោះ កុមារថ្លង់គឺស្ថិតក្នុងសភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទជាងកុមារស្តាប់ឮ ។ ដូច្នេះវាជាការសំខាន់ណាស់ដែលក្រុមគ្រួសារមានកូនថ្លង់ ហើយនឹងអ្នកថែទាំកុមារថ្លង់ទាំងនោះត្រូវតែដឹងអំពីករណីនេះ ។

**រក្សាការពារសុវត្ថិភាពកូនរបស់យើង**

គ្មាននរណាម្នាក់មានសិទ្ធិយកកុមារមកប្រើប្រាស់សំរាប់រួមភេទនោះទេ ។



- មិនមែនជាសមាជិកគ្រួសារ (កុមារ ឬមនុស្សធំ)
- មិនមែនជាមិត្តភ័ក្តិនៃគ្រួសារ
- មិនមែនជាអ្នកជិតខាង
- មិនមែនជាមនុស្សចម្លែក
- មិនមែនជាគ្រូបង្រៀន
- មិនមែនជាអ្នកថែទាំ

មិនមែនជានរណាទាំងអស់!




វាពិតជាការពិបាកមែនក្នុងការនិយាយអំពីការរំលោភបំពានផ្លូវភេទ ។ នៅតាមកន្លែងជាច្រើន :

- មនុស្សទាំងឡាយមិនដឹងអំពី អ្វីទៅដែលហៅថាការរំលោភបំពានផ្លូវភេទ វាកើតឡើងដោយរបៀបណា ហើយវាបណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងណានោះទេ ។
- មនុស្សទាំងឡាយមានអារម្មណ៏មិនស្រួលនៅពេលនិយាយអំពីភេទ ។
- មនុស្សទាំងឡាយមិនចង់ជឿថា ការរំលោភបំពានផ្លូវភេទកើតឡើងចំពោះកុមារតូចៗឡើយ ហេតុនេះទើបពួកគេមិនគិត ឬមិននិយាយអំពីបញ្ហានេះ ។
- ច្បាប់ ឬទំនៀមទម្លាប់បានកំណត់ថា តើនរណាអាចនិយាយទៅកាន់កុមារអំពីរឿងភេទ អ្វីខ្លះដែលអាចយកមកនិយាយបាន ហើយនៅពេលណាដែលការសន្ទនាប្រភេទនេះអាចកើតឡើង ។

**កុមារគ្រប់រូបគួរតែមានសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ ។ ការថែរក្សាកុមារឱ្យសុខសាន្តចៀសផុតពីការរំលោភបំពានគឺជាការទទួលខុសត្រូវរបស់មនុស្សពេញវ័យគ្រប់រូប ។**

## ការពិតមួយចំនួនអំពីការរំលោភបំពានផ្លូវភេទកុមារ

ការរំលោភបំពានផ្លូវភេទកុមារមានន័យថា ការប្រើប្រាស់កុមារដើម្បីសកម្មភាពនៃការរួមភេទ។ ការរំលោភបំពានផ្លូវភេទអាចកើតឡើងចំពោះកុមារណាម្នាក់។ វាកើតឡើងនៅគ្រប់បណ្តាសហគមន៍ ទាំងគ្រួសារអ្នកមាន និងអ្នកក្រីក្រ។ វាកើតឡើងចំពោះកុមារទាំងស្រី ទាំងប្រុស។ ការរំលោភបំពានផ្លូវភេទស្ទើរតែទាំងអស់ បានកើតឡើងចំពោះកុមារមានអាយុច្រើនជាង៥ឆ្នាំ តែវាក៏អាចកើតឡើងចំពោះកុមារតូចៗផងដែរ។

យើងមិនបានដឹងថា ការរំលោភបំពានផ្លូវភេទមានលក្ខណៈជារបៀបទូទៅយ៉ាងណានោះទេ ដោយសារកុមារជាច្រើនមិនមាននរណាពន្យល់ប្រាប់ដល់ពួកគេអំពីអ្វីខ្លះដែលកើតឡើង។ ប៉ុន្តែករណីនេះបានកើតឡើងរួចហើយចំពោះកុមារជាច្រើននាក់ យ៉ាងហោចណាស់មានកុមារម្នាក់ក្នុងចំណោមកុមារ4នាក់នៅក្នុងពិភពលោកយើងទាំងមូល បានរងគ្រោះដោយការរំលោភបំពានផ្លូវភេទ។ មានករណីជាច្រើនដែលកុមារអាចត្រូវបានរំលោភបំពាន។ ករណីមួយចំនួនគឺ :-

### ការរំលោភបំពាននៅពេលដែលកុមារត្រូវបាននរណាម្នាក់ប៉ះពាល់

- ការរួមភេទតាមមាត់ (នៅពេលដែលបុរសម្នាក់ញាត់លិង្គរបស់គាត់ទៅក្នុងមាត់របស់កុមារ)។
- ការថើបញ្ចក់ញី ឬឱបកុមារម្នាក់តាមបែបរួមភេទ។
- ការរួមភេទតាមទ្វារមាស ឬតាមទ្វារបន្ទោរបង់លាមក (នៅពេលដែលបុរសម្នាក់ញាត់លិង្គរបស់គាត់ចូលក្នុងយោនី ឬក្នុងរន្ធគូទរបស់កុមារ)។
- ការយកដៃទៅស្ទាបអង្អែលប្រដាប់ភេទ (ត្រង់កន្លែងលាក់កំបាំង) ឬបញ្ជារឱ្យកុមារស្ទាបអង្អែលប្រដាប់ភេទរបស់មនុស្សពេញវ័យ ឬរបស់ក្មេងជំទង់។
- ចាប់បង្ខំឱ្យកុមារធ្វើជាពេស្យាចារ (យកលុយពីការបំរើផ្លូវភេទ)។

### ការរំលោភបំពាននៅពេលដែលកុមារមិនត្រូវបាននរណាម្នាក់ប៉ះពាល

- ការនិយាយអាសអាភាសអំពីការរួមភេទ ឬប្រើរូបភាពអាសអាភាសឱ្យកុមារភ័ន្តភាំង ធ្វើឱ្យកុមារា កុមារីមានអារម្មណ៍រំភើបញ្ជាប់ញ៉ូវនឹងការរួមភេទ ឬក៏បន្សាំកុមារឱ្យស្គាល់រឿងរួមភេទ។
- បង្ខំឱ្យកុមារស្តាប់ ឬមើលមនុស្សឯទៀតរួមភេទ។
- បង្ខំឱ្យកុមារថតរូបស្រាតសំរាប់ការរួមភេទ (រូបភាពស្រាត)។
- បង្ខំឱ្យកុមារមើលរូបភាពស្រាត។



ជនពាលដែលរំលោភបំពានផ្លូវភេទភាគច្រើន គឺជាបុរស។ ហើយកុមាររងគ្រោះស្ទើរតែទាំងអស់ត្រូវបានរំលោភបំពានដោយមនុស្សណាម្នាក់ដែលពួកគេស្គាល់ ដូចជាសាច់ញាតិ មិត្តភ័ក្តរបស់ក្រុមគ្រួសារ ឬញាតិជិតខាងណាម្នាក់។ ការរំលាភបំពានកម្រនឹងបង្កឡើងដោយជនចម្លែកណាស់។ ពេលខ្លះការរំលោភបំពានបានកើតឡើងតាំងយូរមកហើយ ជួនកាលរាប់ឆ្នាំក៏មានដែរ។

ជនពាលទាំងអស់ដែលរំលោភបំពានផ្លូវភេទកុមារ មិនមែនសុទ្ធតែបានប្រើការចាប់បង្ខំដោយកម្លាំងបាយនោះទេ។ ពេលខ្លះបុគ្គលនោះឆក់យកឱកាសប្រើស្ថានភាពនៃការជឿទុកចិត្ត ឬឥទ្ធិពលដើម្បីទាក់ទាញឱ្យកុមារម្នាក់រួមភេទ។ ជនពាលអាចប្រើការបញ្ចុះបញ្ចូល និង "សណ្តោសប្រណី" ប្រើការគំរាមគំហែង និងសម្លុត ឱ្យវត្ថុ ឬរបស់ហូប។ (ជនពាលក៏អាចជាមនុស្សថ្លង់ដែលជាមិត្តភ័ក្តនឹងកុមារផ្ទាល់)។ ទោះបីនរណាម្នាក់ប្រើការបង្ខំដោយកម្លាំងបាយ គំរាមគំហែង ឬ"សណ្តោសប្រណី" ដើម្បីធ្វើឱ្យកុមាររួមភេទជាមួយក៏ដោយ **លទ្ធផលនៃការរំលោភបំពាន គឺនៅតែធ្វើឱ្យកុមារខូចខាតយ៉ាងធ្ងន់ធ្ងរ។**

## ហេតុអ្វីកុមារថ្លង់ប្រឈមមុខនឹងភាពងាយរងគ្រោះនៃការរំលោភបំពានផ្លូវភេទ?

កុមារថ្លង់គ្រប់រូបស្ថិតនៅក្នុងភាពងាយរងគ្រោះមួយចំនួននៃការរំលោភបំពានផ្លូវភេទ ពីព្រោះពួកគេត្រូវជឿទុកចិត្តលើមនុស្សធំ និងកុមារធំៗ ហើយពឹងផ្អែកលើការថែទាំពីមនុស្សធំៗទាំងនោះ ។ កុមារត្រូវបានគេបង្រៀនថា "កុមារល្អ" ត្រូវតែធ្វើតាមបង្គាប់ដែលមនុស្សធំបានប្រាប់ ។ កុមារតូចៗមានអាយុតិច ក៏គ្មានវិធីណាដឹងពីរបៀបមនុស្សធំប្រព្រឹត្តខ្លួនតាមធម្មតានោះទេ ឬក៏អ្វីទៅជាអាកប្បកិរិយាមនុស្សធំដែលអាចទទួលយកបាន ។

ជាពិសេសកុមារថ្លង់ស្ថិតក្នុងភាពងាយរងគ្រោះចំពោះការរំលោភបំពានផ្លូវភេទ ដោយសារតែ :-

- ជាទូទៅសង្គមបានឱ្យតម្លៃជនពិការទាបជាងមនុស្សដទៃទៀត ។ ដូច្នេះជនពាលអាចគិតថា វាមិនជាអ្វីនោះទេក្នុងការប្រើកុមារសំរាប់ការរួមភេទ ។ ហើយដោយសារតែក្មេងស្រីមានតម្លៃទាបជាងក្មេងប្រុស នោះក្មេងស្រីថ្លង់កាន់តែមានតម្លៃទាបជាងក្មេងប្រុសថ្លង់ទៅទៀត ។ ដូច្នេះហើយក្មេងស្រីថ្លង់ គឺស្ថិតក្នុងគ្រោះមហន្តរាយស្ទើរតែទាំងស្រុង ។
- មនុស្សថ្លង់ប្រើការប៉ះដៃ ស្ទាបស្ទា ដើម្បីប្រាស្រ័យទាក់ទង ឧទាហរណ៍ដូចជា ការចង់បានចំណាប់អារម្មណ៍ពីនរណាម្នាក់ កុមារថ្លង់ម្នាក់អាចគិតថា ការប៉ះ ឬស្ទាបពីបុគ្គលណាម្នាក់ អាចមិនអីនោះទេ ទោះបីវាជាបញ្ហាក៏ដោយ ។
- កុមារថ្លង់ទទួលបានព័ត៌មានតិចជាងកុមារស្តាប់ឮ ប៉ុន្តែ គឺនៅតែមានចម្ងល់ដូចគ្នា ។ ពួកគេក៏អាចនៅដាច់តែឯង ឬមានអារម្មណ៍ឯកោ ដែលធ្វើឱ្យពួកគេក្លាយជាគោលដៅដ៏ងាយស្រួលសំរាប់ជនពាល ។
- កុមារថ្លង់ដែលការប្រាស្រ័យទាក់ទងនៅមានកំរិត ប្រហែលជាបានរៀនធ្វើអ្វីមួយ ដែលមនុស្សឯទៀត ចង់ឱ្យគេធ្វើដោយមិនចាំបាច់សួរថា ហេតុអ្វី ។
- កុមារថ្លង់ដែលបំណិនប្រាស្រ័យទាក់ទងនៅមានកំរិត អាចមិនទាន់យល់បានពេញលេញនូវអ្វីដែលអ្នកបានពន្យល់ប្រាប់ អំពីសុវត្ថិភាពរបស់ពួកគេ ។
- ការប្រាស្រ័យទាក់ទងនៅមានកំរិត ក៏ធ្វើឱ្យកុមារថ្លង់កាន់តែពិបាកប្រាប់អំពីការរំលោភបំពាន ។ នរណាម្នាក់អាចរំលោភបំពានកុមារថ្លង់ម្នាក់ ពីព្រោះជនពាលដឹងថាក្មេងនោះមិនអាចនិយាយកើត អំពីហេតុការណ៍ដែលបានកើតឡើង ។ កុមារថ្លង់ប្រហែលជាអាចប្រាស្រ័យទាក់ទងបានតែជាមួយសមាជិកគ្រួសារ ឬក៏អ្នកថែទាំពួកគេប៉ុណ្ណោះ ។ បើសិនជាជនពាល គឺជាសមាជិកគ្រួសារ អ្នកថែទាំ ឬក៏គ្រូបង្រៀន នោះកុមារអាចមិនមានសុវត្ថិភាពក្នុងចិត្តដើម្បីនិយាយប្រាប់នរណាម្នាក់ឡើយ ។



## ការរំលោភបំពានផ្លូវភេទបង្កទុក្ខទោសដ៏យូរអង្វែង

ការរំលោភបំពានផ្លូវភេទបង្កទុក្ខទោសដល់កុមារនៅចន្លោះពេលដែលការរំលោភបំពានកើតឡើង ហើយវាអាចបន្តធ្វើទុក្ខទោមម្នេញដល់ជនរងគ្រោះនៅពេញមួយជីវិតរបស់គេ។ ជាពិសេសនេះជាការពិត បើសិនជាកុមារមិនអាចនិយាយកើតអំពីហេតុការណ៍រំលោភបំពាន ឬទទួលបានការជួយសង្គ្រោះ គាំទ្រ និងការព្យាបាល។

### ទុក្ខទោសរាងកាយដ៏យូរអង្វែង

ទុក្ខទោសរាងកាយដ៏យូរអង្វែងអាចបង្កដោយជំងឺឆ្លងតាមរយៈការរួមភេទ។ ជនពាលអាចចម្លងជំងឺអេដស៍ និងជំងឺថ្លើមដល់កុមារ ហើយជំងឺទាំងនេះមិនអាចព្យាបាលជាឡើយ។ បើជំងឺឆ្លងតាមរយៈការរួមភេទត្រូវបានទុកចោលមិនព្យាបាល នោះវាអាចបង្កបញ្ហាទៅថ្ងៃមុខដូចជា មានផ្ទៃពោះ មហារីក និងអាចស្លាប់ដោយសារជំងឺដ៏ធ្ងន់ធ្ងរ។ កុមារដែលមានជំងឺឆ្លងពីការរំលោភបំពានផ្លូវភេទ ជាញឹកញាប់មិនបង្ហាញរោគសញ្ញាអ្វីមួយឱ្យដឹងឡើយ ដូច្នេះហើយពួកគេមិនដែលបានព្យាបាលរោគនោះទេ។



### ការខូចខាតចំពោះការអភិវឌ្ឍកុមារ

កុមាររងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ គឺតែងតែមានអារម្មណ៍ថា ខ្លួនមានទោសកំហុសយ៉ាងធំខ្មាសគេ និងខឹងសម្បារ។ ជនរងគ្រោះដោយសារការរំលោភបំពានភាគច្រើន គឺមិនងាយជឿទុកចិត្តអ្នកណាឡើយ។

### វដ្តនៃការរំលោភបំពាន

កុមាររងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ អាចនៅតែមានការរំលោភបំពានជាបន្តដោយមនុស្សរងទៀតនៅពេញមួយជីវិតរបស់គេ។ ដោយសារតែពួកគេបានជួបប្រទះបទពិសោធន៍រំលោភបំពានក្នុងវ័យកុមារ ពេលធំឡើងពួកគេអាចជឿជាក់ថា ការរួមភេទគឺជាវិធីតែម្យ៉ាងដើម្បីទទួលបានសេចក្ដីស្រឡាញ់ ឬសន្តិសុខ។ ដោយធ្លាប់បានជនពាលប្រព្រឹត្តអាក្រក់ និងបានជួបប្រទះការរំលោភបំពានផ្លូវភេទ រឿងហេតុទាំងនេះអាចក្លាយជាលំនាំមួយក្នុងជីវិតរបស់ពួកគេ។




ដោយគ្មានការគាំទ្រ និងការជួយព្យាបាលបញ្ហារំលោភបំពានឱ្យជាសះស្បើយ ក្មេងប្រុសដែលរងគ្រោះដោយសារការរំលោភបំពានអាចក្លាយជាជនពាល ពេលពួកគេធំឡើង។ វដ្តនៃការរំលោភបំពាននេះ អាចបង្កើតទៅជាជំនាន់មួយផ្សេងនៃជនរងគ្រោះ និងជាជនប្រព្រឹត្តបទល្មើសនាពេលអនាគត។

ទុក្ខទោសដែលបានបង្កដោយការរំលោភបំពានកុមារ គឺមិនចំពោះតែកុមារ និងក្រុមគ្រួសារប៉ុណ្ណោះទេ តែសហគមន៍ទាំងមូលផងដែរ។ ឧទាហរណ៍ មនុស្សដែលទទួលភាពអាម៉ាស់ដោយអយុត្តិធម៌ និងនៅដាច់ឆ្ងាយពីគេឯងដោយសារការរំលោភបំពានផ្លូវភេទ ពេលខ្លះពួកគេអាចក្លាយជាមនុស្សដែលបំផ្លិចបំផ្លាញ ឬប្រព្រឹត្តអំពើហឹង្សា ឬទៅជាជនប្រមឹក និងមនុស្សញៀនថ្នាំខុសច្បាប់។

## ទប់ស្កាត់ការរំលោភបំពានផ្លូវភេទ

របៀបដែលមនុស្សដទៃបានប្រព្រឹត្តអំពើអ្វីមួយមកលើខ្លួនយើង គឺធ្វើឱ្យប៉ះពាល់ដល់ការឱ្យតម្លៃខ្លួនរបស់យើង ។ នៅពេលមនុស្សចាត់ទុកកុមារថាគ្មានប្រយោជន៍ និងគ្មានសង្ឃឹម នោះកុមារក៏មើលឃើញខ្លួនឯងថាគ្មានប្រយោជន៍ និងគ្មានសង្ឃឹមទៅតាមនោះដែរ ។ ដូច្នេះយើងត្រូវតែបង្រៀនកុមារឱ្យមានអារម្មណ៍គោរពស្រឡាញ់ខ្លួនឯង ដូច្នេះកុមារនឹងមានទំនុកចិត្តលើខ្លួនឯង និងអាចការពារខ្លួនឯងបានកាន់តែប្រសើរឡើង ។




**ដើម្បីថែរក្សាកុមារឱ្យមានសុវត្ថិភាព យើងត្រូវផ្តល់ចំណេះដឹង បំណិន និងទំនុកចិត្តឱ្យពួកគេ ដើម្បីប្រឆាំងនឹងអាកប្បកិរិយាពុំគប្បីខាងផ្លូវភេទ ទោះបីជាជនពាលនោះ ធំជាង ខ្លាំងជាង ឬមានអំណាចជាងខ្លួនក៏ដោយ ។**

## ជួយកូនឱ្យយល់ និងប្រាស្រ័យទាក់ទងអំពីការរំលោភបំពានផ្លូវភេទ

កុមារថ្លង់រៀនបានងាយស្រួលភាគច្រើន តាមរយៈការមើលឃើញអ្វីៗទាំងឡាយ ។ សញ្ញា កាយវិការ រាងកាយ និងការសំដែងទឹកមុខ រួមគ្នានឹងកាតរូបភាព ឆាកល្ខោនតុក្កតា និងការសំដែងតួ អាចជួយដល់អ្នកក្នុងការបង្រៀនកុមារថ្លង់នូវរបៀបការពារសុវត្ថិភាពខ្លួនឯងពីការរំលោភបំពាន ។ ជួយកុមារឱ្យយល់ថា :-

- ប្រភេទការប៉ះ ឬស្ទាបអង្អែលមួយចំនួន គឺមិនសមរម្យទេ (ការចាប់ដៃរលាក់ គឺមិនអីទេ ។ ការឱបក៏ប្រហែលជាមិនអីដែរ ។ ប៉ុន្តែការប៉ះ ឬស្ទាបអង្អែលត្រង់កន្លែងប្រដាប់ភេទ គឺមិនបានជាដាច់ខាត ហើយការដាក់លិង្គចូលក្នុងមាត់កុមារ គឺមិនបានជាដាច់ខាត) ។
- នាងគួរប្រាប់អ្នកឱ្យដឹងនូវអ្វីមួយដែលកើតឡើង ហើយនាងមិនពេញចិត្ត ។
- នាងអាចជំទាស់ បើសិនជានរណាម្នាក់ព្យាយាមប៉ះ ឬស្ទាបអង្អែលនាងតាមរបៀបរួមភេទ ។

ន័យរបស់ពាក្យ "លាក់កំបាំង" "សម្ងាត់" "ជឿទុកចិត្ត" "សុវត្ថិភាព" និងសញ្ញាសំរាប់ពាក្យទាំងនេះ គឺពិបាកនឹងពន្យល់ប្រាប់កុមារតូចៗខ្លាំងណាស់ ជាពិសេសបើពួកគេជាកុមារថ្លង់ ។

ចូរប្រើសញ្ញាខុសៗគ្នា កាយវិការ រូបភាព និងពាក្យនិយាយទាល់តែអ្នកប្រាកដក្នុងចិត្តថាកូនយល់ន័យនោះហើយ ។ ចូរសំដែងតួនៅក្នុងស្ថានភាពនោះជាមួយកូន ឬប្រើកូនតុក្កតា ឬរូបភាពដើម្បីព្យាយាមបង្ហាញន័យទាំងអស់នេះឱ្យបានច្រើនរបៀបដែលអ្នកអាចធ្វើបាន ។



## ឧទាហរណ៍សញ្ញាខ្លះៗដែលអាចជួយអ្នកក្នុងការពន្យល់អំពីការរំលោភបំពានផ្លូវភេទ

សញ្ញាទាំងនេះភាគច្រើនគឺជាភាសាសញ្ញាកម្ពុជា និងមានសញ្ញាកម្ម៉ីមួយចំនួនតូចពីភាសាសញ្ញាអាមេរិក។ ត្រូវចាំថា សញ្ញាក្នុងស្រុកភូមិរបស់អ្នកផ្ទាល់ គឺប្រហែលជាខុសប្លែកពីនេះ។




## ជួយកុមារឱ្យចេះដាក់ឈ្មោះ និងរៀបរាប់អំពីជនពាល

ការដាក់ឈ្មោះសញ្ញាឱ្យមនុស្សគ្រប់គ្នា និងបង្រៀនកូនឱ្យស្គាល់គ្រប់ឈ្មោះមនុស្សទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។ ហាត់រៀនសំគាល់មើលឱ្យល្អិតល្អន់អំពីមនុស្ស និងទីកន្លែង ហើយប្រាស្រ័យទាក់ទងអំពីពួកគេទាំងនោះជាមួយកូនអ្នក។ បង្រៀនកូនអ្នកនូវពាក្យរៀបរាប់អំពីមនុស្សដូចជា ខ្ពស់ ទាប សក់ឬរោមច្រើន ធាត់ ស្គម និងអ្វីផ្សេងទៀត។ នៅពេលកូនអាចរៀបរាប់ពីបុគ្គលម្នាក់ កូនអាចរៀបរាប់ពីជនពាលបាន។

### ដាក់ឈ្មោះជាសញ្ញាឱ្យមនុស្សគ្រប់គ្នា



កូនស្រីម្នាក់ក្នុងចំណោមកូនស្រីតូចៗរបស់យើង ជាក្មេងស្រីថ្លង់អាយុ6ឆ្នាំ ហើយត្រូវបានជនពាលចាប់រំលោភ។ ប៉ូលីសបានស្នើឱ្យយើងសួរនាង អំពីនរណាម្នាក់បានប្រព្រឹត្តអំពើនេះមកលើនាង។ នាងមិនអាចផ្តល់ចម្លើយបានឡើយ។ ហេតុផលមួយគឺថា នាងគ្មានឈ្មោះសញ្ញាសំរាប់មនុស្សទាំងអស់ដែលរស់នៅជុំវិញនាង។ ឥឡូវនេះយើងជំរុញលើកទឹកចិត្តឪពុកម្តាយទាំងឡាយ ឱ្យដាក់ឈ្មោះជាសញ្ញាដល់មនុស្សទាំងអស់ដែលពាក់ព័ន្ធក្នុងជីវិតរបស់ក្មេង។ តាមវិធីនេះ នរណាម្នាក់ដែលបង្កការឈឺចាប់ដល់កុមារអាចនាំមកកាត់ទោសតាមផ្លូវច្បាប់។

**– មជ្ឈមណ្ឌលកុមារថ្លង់ នៅប្រទេសហ្ស៊ីមបាវេ ទ្វីបអាហ្វ្រិក**

# សកម្មភាព

នេះគឺជាសកម្មភាពមួយចំនួន ដើម្បីជួយការពារសុវត្ថិភាពកូនរបស់អ្នកពីការរំលោភបំពានផ្លូវភេទ។

## ▶ វិធីជួយកូនអ្នកឱ្យយល់ថា ចំណែកខ្លះៗនៃរាងកាយគឺជាកន្លែងលាក់កំបាំង

ពន្យល់ប្រាប់កូនថា ខ្លួនប្រាណនាងគឺជារបស់នាងតែម្នាក់ឯងគត់ និងចំណែកខ្លះៗនៃរាងកាយគឺជាកន្លែងលាក់កំបាំងជាងកន្លែងផ្សេងទៀត។ ពន្យល់ប្រាប់កូនថា មនុស្សធំ ឬកុមារធំៗមិនគួរប៉ះពាល់ប្រដាប់ភេទ (យោនី) ឬកន្លែងលាក់កំបាំងរបស់នាងឡើយ ហើយនាងផ្ទាល់ក៏មិនគួរប៉ះពាល់កន្លែងលាក់កំបាំងរបស់មនុស្សធំនោះទេ ទោះបីជានរណាបង្គាប់ឱ្យប៉ះកន្លែងនោះក៏ដោយ។ ចូរប្រើតុក្កតា ឬរូបភាព និងបង្ហាញតាមរយៈកាយវិការរាងកាយ និងសំដែងទឹកមុខ ថាកន្លែងនេះអាចមិនអីទេ ហើយកន្លែងនោះកុំប៉ះដាច់ខាត។ ត្រូវតែពន្យល់កូនផងដែរថា បើសិនជានរណាម្នាក់ឱ្យកូនអ្នកមើលកន្លែងលាក់កំបាំង ឬឱ្យមើលរូបភាពលាក់កំបាំងអ្វីមួយ អំពើបែបនេះត្រូវតែជំទាស់ជាដាច់ខាត។




នៅពេលកូនអ្នកមានអាយុរចន្លោះពី 3ទៅ5ឆ្នាំ បង្រៀនកូនអំពីភេទ និងចំណែកលាក់កំបាំងនៃរាងកាយ ហើយអំពីភាពខុសគ្នានៃរាងកាយរវាងក្មេងប្រុស និងក្មេងស្រី។

ទាំងនេះគឺជាគំនិតដែលពិបាកបង្រៀន ចូរប្រើវិធីសាស្ត្រខុសៗគ្នាដើម្បីព្យាយាមធ្វើយ៉ាងណាឱ្យកូនអ្នកបានយល់។ ការបង្រៀនអាចកើតឡើងតាមធម្មតា ឧទាហរណ៍អំឡុងពេលកូនអ្នកស្លៀកពាក់ខោអាវ។ អ្នកអាចប្រើកូនតុក្កតាដើម្បីបង្រៀនអំពីចំណែកនៃរាងកាយ។

## ▶ របៀបជួយកូនរៀនធ្វើសូរសម្លេង ឬស្រែកឱ្យជួយ

កុមារថ្លង់ជាច្រើនមិនចូលចិត្តប្រើសម្លេងរបស់ពួកគេនោះទេ។ ប្រការនេះដោយសារតែការសើចចំអក ឬក៏នៅពេលកុមារថ្លង់បញ្ចេញសម្លេងត្រូវបានមនុស្សឯទៀតប្រាប់ថា សម្លេងរបស់ពួកគេគឺចម្លែកគួរឱ្យអស់សំណើច។ ពន្យល់ប្រាប់កូនអ្នកថា បើសិនជានរណាឆាឆៅកូន ហើយកូនត្រូវការឱ្យជួយ នោះការស្រែកឱ្យជួយគឺមិនអីទេ។

បង្រៀនកូនថា កូនគួរតែស្រែក "ទេ! ទេ!" ឬក៏ "ជួយផង! ឬទន្រ្ទាំជើងឱ្យខ្លាំងៗ បើសិនជាមនុស្សធំ ឬក្មេងធំព្យាយាមធ្វើឱ្យកូនឈឺចាប់។ កូនក៏អាចស្រែកឱ្យខ្លាំងអស់សម្លេង ខាំ និងប្រតាយប្រតប់តបទៅវិញ។ ចូរប្រើតុក្កតា ឬសំដែងតួ ដើម្បីបង្ហាញកូនអំពីន័យដែលអ្នកចង់ឱ្យកូនយល់។



## ▶ របៀបជួយកូនឱ្យរៀននិយាយ ទេ!

ជាញឹកញាប់កុមារថ្លង់មិនយល់ថា **ហេតុអី**ពួកគេគួរធ្វើ ឬមិនគួរធ្វើអ្វីមួយពិតប្រាកដ ឬក៏ហេតុអ្វីបានជាហេតុការណ៍នោះកើតឡើងចំពោះពួកគេ។ ពួកគេចង់ផ្គាប់ចិត្តមនុស្ស ដូច្នេះហើយពួកគេរៀនធ្វើតាមបង្គាប់ដោយគ្មានសួរហេតុផល។ ប្រការនេះអាចជាបញ្ហាមួយ បើសិនជានរណាម្នាក់ប្រាប់ពួកគេឱ្យធ្វើអ្វីមួយដែលខុសឆ្គង។

សូមជួយកូនឱ្យហាត់និយាយថា "ទេ!"។ ដំបូង ព្យាយាមប្រឌិតស្ថានភាពនៅក្នុងករណីដែលកុមារម្នាក់អាចចង់និយាយថា "ទេ!"។




ពេលក្រោយ ចូរជជែកគ្នាអំពីការនិយាយថា "ទេ!" និងកន្លែងណាដែលកូនអាចហៅឱ្យជួយ។




ឱ្យកូនប្រាប់អ្នក ឬក៏មនុស្សធំណាម្នាក់ទៀតភ្លាមៗ បើសិនជាមាននរណាម្នាក់ឱ្យកូនធ្វើអ្វីមួយដែលកូនមានអារម្មណ៍មិនពេញចិត្តនឹងធ្វើ។



### ▶ របៀបជួយកូនអ្នកឱ្យយល់ថា គេមិនត្រូវធ្វើតាមបង្គាប់មនុស្សធំជានិច្ចនោះទេ

នៅពេលដែលកុមារចេះនិយាយតបវិញថា "ទេ!" អ្នកអាចប្រឌិតស្ថានភាពនៅក្នុងសភាពដែលថា កុមារមិនត្រូវស្តាប់បង្គាប់មនុស្សធំ ។




### ▶ របៀបជួយកូនឱ្យស្គាល់កន្លែងដែលទៅរកឱ្យគេជួយ

តើនរណាដែលកូនរបស់អ្នកអាចទៅរកឱ្យជួយ? កុមារគ្រប់រូបគួរតែមានយ៉ាងហោចណាស់មនុស្សបីនាក់ ដែលកូនអាចទៅរកឱ្យជួយបាននៅពេលមានបញ្ហា ។ បុគ្គលទាំងនេះអាចជាម្តាយ ឪពុក មីង អ្នកជិតខាង ឬក៏បុគ្គលណាម្នាក់ដែលអ្នក និងកូនជឿទុកចិត្តក្រៅពីក្រុមគ្រួសារ ដូចជាម្តាយរបស់កុមារម្នាក់ផ្សេងទៀត ។

កុមារគួរតែដឹងថា កាលណាបុគ្គលម្នាក់មិននៅ ឬមិនយកចិត្តទុកដាក់ កុមារគួរទៅរកមនុស្សម្នាក់ទៀតឱ្យជួយខ្លួន ។ ចូរពន្យល់ប្រាប់មនុស្សទាំងអស់ដែលអ្នកកំពុងបង្រៀនឱ្យដឹងថា កុមារនឹងទៅរកពួកគេឱ្យជួយ បើសិនជាចាំបាច់ ។ ចូរអនុវត្តជាមួយកូននូវរបៀបទៅរកមនុស្សឱ្យជួយខ្លួនក្នុងករណីខុសៗគ្នា ។



## តើខ្ញុំអាចដឹងដោយរបៀបណាថា កូនខ្ញុំត្រូវបានជនពាលរំលោភបំពាន?

នៅពេលដែលកុមារតូចត្រូវបានជនពាលរំលោភបំពាន ពួកគេអាចភ័យខ្លាចនឹងប្រាប់អ្នក។ ជាញឹកញាប់ជនពាលតែងតែព្រមានកុមារមិនឱ្យនិយាយអ្វីឡើយ។ ពេលខ្លះកុមារខ្លាចដោយយល់ថាគេបានធ្វើអ្វីមួយខុសឆ្គង។ ឬកុមារមិនដឹងរបៀបប្រាស្រ័យទាក់ទងអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន។

ដោយហេតុថា កុមារតែងតែមិនប្រាស្រ័យទាក់ទងអំពីការរំលោភបំពាន អ្នកត្រូវចេះសំគាល់មើលសញ្ញាចម្លែកដែលអាចកើតមាន។ សញ្ញាសំគាល់ដូចខាងក្រោមនេះ មិនមែនជាលទ្ធផលនៃការរំលោភបំពាន**ជានិច្ចនោះទេ** ប៉ុន្តែពួកវាជាភិនភាគនៃមូលហេតុដែលគួរឱ្យខ្វល់ខ្វាយ ជាពិសេសបើកុមារបង្ហាញសញ្ញាសំគាល់មួយចំនួន។

**សញ្ញាខ្លះៗដែលចម្លែកលើរាងកាយ រួមមាន :-**

- ការឈឺចាប់គ្មានមូលហេតុ ហើម ឬស្នាមក្រហម ឬហូរឈាមចេញតាមមាត់ តាមប្រដាប់ភេទ ឬនៅជុំវិញទ្វារធំ។
- ខោទ្រនាប់រហែក ឬប្រឡាក់ឈាម។
- លំបាកបន្ទោរបង់លាមក ឬជុះនោម។
- ធ្លាក់សពីទ្វារមាស ឬហូរខ្ទុះចេញតាមបង្ហួរនោម ឬទ្វារបន្ទោរបង់ ឬកើតជំងឺឆ្លងតាមការរួមភេទ ដែលមិនធម្មតា។
- ស្នាមជាំ ឈឺក្បាល ឬឈឺពោះ។

**កុមារត្រូវបានជនពាលរំលោភបំពានផ្លូវភេទ អាច :-**

- ឈប់ងូតទឹក ឬលាងខ្លួនដែលមិនមែនជាទម្លាប់ធម្មតា ឬជំទាស់មិនព្រមផ្លាស់សំលៀកបំពាក់។
- លេងជាមួយកុមារឯទៀត ឬប្រដាប់លេងតាមរបៀបរួមភេទ ឬដឹងពីអ្វីៗទាក់ទងនឹងភេទលឿនជាងវ័យរបស់ពួកគេ។
- ដឹងរឿងភេទច្រើនជាងក្មេងៗដែលមានអាយុស្រករគ្នា។

**កុមាររងគ្រោះដោយអំពើហឹង្សា រួមទាំងការរំលោភបំពានផ្លូវភេទ អាច :-**

- ហាក់ដូចជាភ័យខ្លាច អារម្មណ៍ងាយប្រែប្រួល និងប្រយ័ត្នប្រយែង ឬស្រាប់តែខ្លាចមនុស្ស ឬកន្លែងណាមួយភ្លាមមួយរំពេច ឬក៏ចង់នៅតែជាមួយឪពុកម្ដាយរបស់ខ្លួនតែប៉ុណ្ណោះ។
- ជាក្មេងមានភាពអាថិកំបាំងសម្ងាត់ ឬចង់នៅតែម្នាក់ឯងស្ទើរតែគ្រប់ពេលវេលា។
- ចាប់ផ្ដើមធ្វើឬកពារដូចកូនក្មេងតូច ដូចជាចិតកូនក្មេងបៀមដៃអញ្ចឹង។
- ក្លាយជាមានទោសៈហឹង្សាកាន់តែខ្លាំង ឬកោងកាច។
- ព្យាយាមរត់ចោលផ្ទះ។
- អារម្មណ៍សោកសៅស្ទើរគ្រប់ពេលវេលា ឬបង្ហាញថាមិនមានអារម្មណ៍នៅក្នុងខ្លួនសោះ។
- ពិបាកដេក ពីព្រោះយល់សប្តិអាក្រក់ ខ្លាចទីងងឹត និងជុះនោមដាក់គ្រែដេក។
- ខ្លាចគេឯងប៉ះពាល់ ឬសកម្មភាពរាងកាយ។



**បើសិនជាអ្នកសង្ស័យថាមានការរំលោភបំពាន**

សូមព្យាយាមធ្វើចិត្តស្ងប់ ។ លើកទឹកចិត្តកូនឱ្យបង្ហាញអ្នកនូវអ្វីដែលបានកើតឡើង ឬក៏អ្វីដែលកូនដឹង ។

ដើម្បីបានព័ត៌មានបន្ថែមទៀត បង្កើតស្ថានភាពលេងជាមួយកូនអ្នក ។ សូមយកចិត្តទុកដាក់ឱ្យប្រយ័ត្នជាទីបំផុតចំពោះអ្វីដែលកូនបង្ហាញអ្នក ពីព្រោះកូនអាចមិនមានពាក្យ ឬសញ្ញាគ្រប់គ្រាន់ដើម្បីពន្យល់ខ្លួនឯងឱ្យបានច្បាស់លាស់ ។ តាមរយៈសម្លេង និងទឹកមុខរបស់អ្នក ចូរធ្វើយ៉ាងណាឱ្យកូនដឹងថាអ្នកជឿកូន និងមិនដាក់ទណ្ឌកម្មកូន ។

## បើសិនជាកូនអ្នកត្រូវបានជនពាលរំលោភបំពានផ្លូវភេទ

បើសិនជាកូនអ្នកត្រូវបានជនពាលរំលោភបំពានផ្លូវភេទ អ្នកអាចជួយបាន បើសិនជាអ្នក :-

- ជឿជាក់លើអ្វីដែលកូនបង្ហាញ ឬប្រាស្រ័យទាក់ទងជាមួយអ្នក ។ វាអាចមានការពិបាកជឿថា បុគ្គលម្នាក់ដែលអ្នកស្គាល់ និងទុកចិត្តបានប្រព្រឹត្តអំពើថោកទាបមកលើកូនរបស់អ្នក ប៉ុន្តែកូនរបស់អ្នកកម្រនឹងប្រឌិតអំពីការរំលោភបំពានផ្លូវភេទណាស់ ។ ជនពាលខ្លះ គឺចេះផ្អែមល្ហែមយកចិត្តចំពោះឪពុកម្តាយណាស់ ។ តាមវិធីនេះ ជនពាលបានផលចំណេញពីកុមារ និងបង្អាក់ឪពុកម្តាយមិនឱ្យរាយការណ៍អំពីការរំលោភបំពាន ។



- ចូរសរសើរកូនដែលបានប្រាប់អ្នក ។ កុមារត្រូវការដឹងថា គេបានធ្វើអ្វីមួយត្រឹមត្រូវដោយការប្រាស្រ័យទាក់ទងអំពីការរំលោភបំពាន ។
- រំលឹកឱ្យកូនមានលំនឹងចិត្តសារជាថ្មីថា ការរំលោភបំពាននេះមិនមែនជាកំហុសរបស់កូននោះទេ ហើយប្រាប់កូនថាអ្នកមិនខឹងនឹងកូនឡើយ ។ សូមប្រើវិធីផ្សេងៗពីគ្នាដើម្បីប្រាស្រ័យទាក់ទងលើករណីនេះ តាមដែលអាចធ្វើបាន ។
- ចូរការពារសុវត្ថិភាពរបស់កូន ។ ព្យាយាមបង្ការការទាក់ទងរវាងកូនអ្នក និងជនពាលនៅពេលអនាគត ។ បើសិនជាប្រការនេះមិនអាចធ្វើបាន អ្នកត្រូវធ្វើយ៉ាងណា ឬត្រូវមាននរណាម្នាក់ដែលដឹងរឿងកើតឡើងពីមុននៅជាមួយកូនជានិច្ច ខណៈពេលមានវត្តមានរបស់ជនពាលនោះ ។
- ព្យាបាលបញ្ហាសុខភាពរាងកាយពីការរំលោភបំពាន ។ ព្យាយាមនាំកូនទៅធ្វើតេស្តអំពីជំងឺឆ្លងតាមការរួមភេទ ទោះបីជាកូនមិនមានរោគសញ្ញាអ្វីចម្លែកក៏ដោយ ។ ជំងឺឆ្លងតាមការរួមភេទខ្លះមិនបង្ហាញរោគសញ្ញាអ្វីមួយឡើយ ឬរោគសញ្ញានោះមិនបង្ហាញពេលរឿងហេតុកើតឡើងថ្មីៗទេ ទាល់តែកុមារធំបន្តិចទើបរោគសញ្ញានោះបង្ហាញឡើង ។

ក្នុងនាមជាឪពុកម្តាយ អ្នកក៏ត្រូវការជួយជ្រោមជ្រែងផងដែរ ។ ឪពុកម្តាយមានអារម្មណ៍វិជ្ជលចិត្តជាច្រើន រួមមានការមិនជឿជាក់ ខឹងម៉ូម៉ៅ និងសោកសៅយ៉ាងខ្លាំង នៅពេលពួកគាត់បានដឹងថាកូនរបស់ខ្លួនត្រូវបានជនពាលរំលោភបំពាន ។ ឪពុកម្តាយអាចបន្ទោសខ្លួនឯង ឬបន្ទោសគ្នាទៅវិញទៅមកនូវអ្វីដែលបានកើតឡើងចំពោះកូន ។ វាអាចជួយអ្នកឱ្យរំសាយចិត្តក្នុងការនិយាយប្រាប់នរណាម្នាក់ដែលអ្នកទុកចិត្តអំពីអារម្មណ៍ទាំងនេះ ។ អ្នកត្រូវមានចិត្តអំណត់ចំពោះខ្លួនឯង ។ វាអាចចំណាយពេលយ៉ាងយូរដើម្បីរំសាយអារម្មណ៍ទាំងនេះ ។

បើសិនជាកុមារត្រូវបានជនពាលរំលោភបំពាន គឺមិនមានអ្វីត្រូវអាម៉ាស់នោះទេ ។ ការរំលោភបំពានគឺជាបទឧក្រិដ្ឋដូចជាចោរអញ្ចឹង ហើយក្រុមគ្រួសារមិនបានបង្ករឿងនោះឡើយ ។

## ដើម្បីធ្វើឱ្យកាន់តែមានសុវត្ថិភាពចំពោះកុមារក្នុងសហគមន៍

មនុស្សភាគច្រើនតែងមិនស្រួលចិត្ត នៅពេលនិយាយអំពីការរំលោភបំពានផ្លូវភេទ ហើយព្រមទទួលថាកុមារមិនមានសុវត្ថិភាព ឬក៏ពិភាក្សាលើទុក្ខទោសអំពីផលប៉ះពាល់នៃការរំលោភបំពាន។ ផ្ទុយទៅវិញ ការរំលោភបំពានផ្លូវភេទអាចត្រូវបានការពារ បើអ្នកគ្រប់គ្នាអាចនិយាយពីបញ្ហានេះ។




កម្មវិធីប្រជុំនៅក្នុងសាលារៀន និងនៅក្នុងសហគមន៍អាចបង្រៀនសហគមន៍ទាំងមូលអំពីការរំលោភបំពានផ្លូវភេទ។ ការសំដែងឆាកល្ខោន ឬឆាកកំប្លែងខ្លីៗអំពីផលប៉ះពាល់នៃការរំលោភបំពាន ពេលខ្លះអាចធ្វើឱ្យមនុស្សមានការងាយស្រួលជជែកគ្នាជាក្រុមអំពីការរំលោភបំពាន។

នេះគឺជាមធ្យោបាយដ៏ទូលាយដែលសហគមន៍ខ្លះធ្វើការងារស្ដីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ :-

- **សិក្ខាសាលាសំរាប់ឪពុកម្ដាយ និងគ្រូបង្រៀន** ដើម្បីជួយពួកគេរៀនពីវិធីប្រាស្រ័យទាក់ទងនានាជាមួយកុមារតូចៗ អំពីរបៀបការពារការរំលោភបំពានផ្លូវភេទ។ សូមអានឱ្យឮៗជាមួយឪពុកម្ដាយនូវអ្វីដែលបានសរសេរ ឬប្រើប្រាស់សម្ភារៈឱ្យបានច្រើន បើសិនជាការពិភាក្សាមិនអាចធ្វើបាន។
- **ការបណ្ដុះបណ្ដាលសំរាប់គ្រូបង្រៀន បុគ្គលិកធ្វើការនៅក្នុងសាលារៀន វេជ្ជបណ្ឌិត និងភ្នាក់ងារសុខាភិបាល** ធ្វើដូច្នេះពួកគេអាចសំគាល់សញ្ញាចម្លែកដែលកុមារអាចត្រូវបានរំលោភបំពាន និងរៀនពីរបៀបនិយាយទៅរកកុមារដែលប្រហែលជាជនរងគ្រោះដោយសារការរំលោភបំពាន។ រៀបចំសិក្ខាសាលាជាមួយបុគ្គលិកសាលារៀន ដើម្បីពិភាក្សាលើក្រមសីលធម៌នៃការធ្វើការងារជាមួយកុមារ។
- **ការអប់រំសំរាប់កុមារនៅសាលារៀន** ដើម្បីការពារការរំលោភបំពានផ្លូវភេទ។ ការអប់រំនេះ ក៏អាចរួមបញ្ចូលទាំងវ័យដែលសមស្របចំពោះការអប់រំស្ដីពីសុខុមាលភាពនៃផ្លូវភេទផងដែរ។
- **រាយការណ៍អំពីការរំលោភបំពាននៅពេលវាកើតឡើង** អាចការពារវាកុំឱ្យកើតឡើងទៀតនៅពេលអនាគត។ ស្វែងរកទម្រង់បែបបទដែលមានសំរាប់រាយការណ៍អំពីការរំលោភបំពានផ្លូវភេទកុមារ ហើយធ្វើយ៉ាងណាឱ្យប្រាកដថា ព័ត៌មាននេះបានទៅដល់ឪពុកម្ដាយ គ្រូបង្រៀន ភ្នាក់ងារសុខាភិបាល និងអ្នកឯទៀត ដែលអាចរៀនអំពីការរំលោភបំពានផ្លូវភេទកុមារ។ បើមិនមានទម្រង់បែបបទ ចូរធ្វើការបង្កើតឱ្យមានទម្រង់បែបបទមួយ។

**កាលណាមនុស្សកាន់តែច្រើនបានដឹងអំពីបញ្ហានៃការរំលោភបំពាន យើងអាចការពារវាបានកាន់តែច្រើនថែមទៀត ដើម្បីកុំឱ្យវាកើតឡើងចំពោះកូនៗរបស់ពួកយើង។**

